ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ០៧៨ កយ.ប្រក/២៦

# ប្រកាស

# ស្តីពី

# ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក

# ក្នុងទម្រង់ផ្សេងក្រៅពីការលក់ឡាយឡុង

២០២៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :០៧៨កយ.ប្រក/២៦

# ប្រកាស
## ស្តីពី
## ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក ក្នុងទម្រង់ផ្សេងក្រៅពីការលក់ឡាយឡុង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៥/០០២ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ០៩៩ កយ.ប្រក/២៥ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ និងគណៈកម្មការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកនៅតាមសាលាដំបូងរាជធានី ខេត្ត
- បានឃើញប្រកាសលេខ ០២៤ កយ.ប្រក/២៦ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦ ស្តីពីបែបបទ និងនីតិវិធីនៃការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីវិធាននៃការចាត់ចែងជាបណ្ដោះអាសន្នក្នុងទម្រង់ផ្សេងក្រៅពីការលក់ឡាយឡុងនូវវត្ថុចាប់យក ក្នុងរឿងក្ដីព្រហ្មទណ្ឌនៅតាមតុលាការ ស្របតាមមាត្រា១១ នៃច្បាប់ស្ដីពីការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក ដើម្បីធានាប្រសិទ្ធភាព និងតម្លាភាពក្នុងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក ក្នុងគោលបំណងរក្សាតម្លៃសេដ្ឋកិច្ចនៃវត្ថុចាប់យកទាំងនោះ ព្រមទាំងការពារផលប្រយោជន៍របស់ម្ចាស់នៃវត្ថុចាប់យក ឬរបស់បុគ្គលពាក់ព័ន្ធផ្សេងទៀត និងការពារផលប្រយោជន៍សាធារណៈ។

**ប្រការ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក ក្នុងទម្រង់ផ្សេងក្រៅពីការលក់ឡាយឡុង ដែលត្រូវបានធ្វើឡើងនៅគ្រប់ដំណាក់កាលនៃនីតិវិធីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ។

ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នក្នុងទម្រង់ជាការលក់ឡាយឡុង ត្រូវស្ថិតក្នុងវិសាលភាពនៃប្រកាសលេខ ០២៤ កយ.ប្រក/២៦ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦ ស្ដីពីបែបបទ និងនីតិវិធីនៃការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក និងជាសមត្ថកិច្ចរបស់គណៈកម្មការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកនៅតាមសាលាដំបូងរាជធានី ខេត្ត (**គ.ច.ស.ផ.**) ស្របតាមប្រកាសលេខ ០៩៩ កយ.ប្រក/២៥ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥ ស្ដីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ និងគណៈកម្មការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកនៅតាមសាលាដំបូងរាជធានី ខេត្ត។

**ប្រការ៣ .-**

ក្រៅពីការលក់ឡាយឡុង ការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកអាចធ្វើឡើងក្នុងទម្រង់ដូចខាងក្រោម៖

១-ការចាត់ចែងឱ្យគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ដើម្បីជាប្រយោជន៍សាធារណៈ ឬ

២-ការចាត់ចែងដើម្បីធានាតម្លៃ ឬផលប្រយោជន៍សេដ្ឋកិច្ចនៃវត្ថុចាប់យក។

**ប្រការ៤ .-**

ដើម្បីអនុវត្តប្រការ៣ នៃប្រកាសនេះ គណៈកម្មការទទួលបន្ទុកអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកក្រៅពីការលក់ឡាយឡុង (**គ.អ.ច.ប.**) ត្រូវបង្កើតឡើងដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចបង្កើតអង្គភាពរដ្ឋបាល ឬអង្គភាពជំនាញផ្សេងៗដើម្បីជួយដល់គណៈកម្មការនេះ។ **គ.អ.ច.ប.** អាចអញ្ជើញតំណាង ឬអ្នកជំនាញពីស្ថាប័នរដ្ឋ ឬឯកជនចូលរួមផ្ដល់យោបល់លើការគ្រប់គ្រង និងការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក។

**គ.អ.ច.ប.** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- អនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកក្រៅពីការលក់ឡាយឡុង តាមដីកាសម្រេចរបស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ឬតាមសាលក្រម ឬសាលដីការបស់តុលាការ
- តាមដាន និងត្រួតពិនិត្យការគ្រប់គ្រង និងការថែរក្សាដោយស្ថាប័នរដ្ឋ ឬនីតិបុគ្គលឯកជនដើម្បីជាប្រយោជន៍សាធារណៈ
- ផ្ដល់យោបល់ និងលើកសំណើអំពីស្ថាប័នរដ្ឋ ឬនីតិបុគ្គលឯកជនដែលត្រូវទទួលបន្ទុកគ្រប់គ្រង ថែរក្សា និងប្រើប្រាស់វត្ថុចាប់យកដើម្បីជាប្រយោជន៍សាធារណៈ

- ផ្ដល់យោបល់ និងលើកសំណើអំពីទម្រង់ផ្សេងទៀតនៃការចាត់ចែងជាបណ្ដោះអាសន្នជូនអង្គការអយ្យការ ឬតុលាការដែលមានសមត្ថកិច្ច
- អនុវត្តការងារផ្សេងទៀតតាមការសម្រេចរបស់អង្គការអយ្យការ ឬតុលាការ ឬតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៥ ._**

កាលបើអង្គការអយ្យការ ឬតុលាការសម្រេចប្រគល់ឱ្យស្ថាប័នរដ្ឋ ឬនីតិបុគ្គលឯកជនគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ដើម្បីជាប្រយោជន៍សាធារណៈនូវវត្ថុចាប់យកតាមចំណុចទី១ នៃប្រការ៣ នៃប្រកាសនេះ អង្គការអយ្យការ ឬតុលាការត្រូវកំណត់អំពីស្ថាប័នរដ្ឋ ឬនីតិបុគ្គលឯកជនដែលត្រូវទទួលបន្ទុកអនុវត្តកិច្ចការនេះ។ ក្នុងករណីដែលអង្គការអយ្យការ ឬតុលាការមិនអាចកំណត់បានអំពីស្ថាប័នរដ្ឋ ឬនីតិបុគ្គលឯកជនណាមួយជាក់លាក់នៅឡើយ តុលាការអាចប្រគល់វត្ថុចាប់យកនោះឱ្យ **គ.អ.ច.ប.** ដើម្បីពិនិត្យ និងលើកយោបល់អំពីវិធី ឬរបៀបនៃការចាត់ចែងនៃវត្ថុចាប់យកតាមប្រការ៣ នៃប្រកាសនេះ ដើម្បីអង្គការអយ្យការ ឬតុលាការពិនិត្យ និងសម្រេច។

**គ.អ.ច.ប.** ត្រូវទទួលខុសត្រូវក្នុងការតាមដាន និងត្រួតពិនិត្យការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលត្រូវបានប្រគល់ឱ្យស្ថាប័នរដ្ឋ ឬនីតិបុគ្គលឯកជនគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ដើម្បីជាប្រយោជន៍សាធារណៈនូវវត្ថុចាប់យកតាមកថាខណ្ឌទី១ ខាងលើ និងរាយការណ៍ជូនអង្គការអយ្យការ ឬតុលាការដែលមានសមត្ថកិច្ចចាត់ចែងលើវត្ថុចាប់យកនេះ។

**ប្រការ៦ ._**

ក្នុងករណីដែលត្រូវសម្រេចចាត់ចែងដើម្បីជានាតម្លៃ ឬផលប្រយោជន៍សេដ្ឋកិច្ចនៃវត្ថុចាប់យកតាមចំណុចទី២ នៃប្រការ៣ នៃប្រកាសនេះ អង្គការអយ្យការ ឬតុលាការដែលមានសមត្ថកិច្ចត្រូវប្រគល់វត្ថុចាប់យកឱ្យ **គ.អ.ច.ប.** ដើម្បីពិនិត្យ និងលើកយោបល់អំពីវិធី ឬរបៀបនៃការចាត់ចែងដើម្បីជានាតម្លៃ ឬផលប្រយោជន៍សេដ្ឋកិច្ចនៃវត្ថុចាប់យកនោះ។

ការចាត់ចែងដើម្បីជានាតម្លៃ ឬផលប្រយោជន៍សេដ្ឋកិច្ចនៃវត្ថុចាប់យកអាចធ្វើឡើងតាមវិធី ឬរបៀបដូចតទៅ៖

១- ការគ្រប់គ្រង ថែរក្សា និងជួសជុលដើម្បីជានាតម្លៃសេដ្ឋកិច្ចនៃវត្ថុចាប់យក
២- ការជួល ឬការបង្កើតកិច្ចសន្យាផ្សេងទៀតដែលមិនមានអានុភាពផ្ទេរកម្មសិទ្ធិដើម្បីជានាផលប្រយោជន៍សេដ្ឋកិច្ចនៃវត្ថុចាប់យក
៣- ការបន្តកិច្ចសន្យាផ្សេងៗលើវត្ថុចាប់យកដែលមានសកម្មភាពអាជីវកម្ម ឬពាណិជ្ជកម្មក្នុងលក្ខខណ្ឌដែលកិច្ចសន្យាទាំងនេះមិនមានអានុភាពផ្ទេរកម្មសិទ្ធិលើវត្ថុចាប់យក
៤- ការចាត់តាំងអង្គភាពរដ្ឋ ឬតំណាងដើម្បីអនុវត្តសិទ្ធិ ឬចូលរួមអនុវត្តសិទ្ធិនៅក្នុងសកម្មភាពអាជីវកម្ម ឬពាណិជ្ជកម្មក្នុងករណីដែលវត្ថុចាប់យកគឺជាភាគហ៊ុន ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត
៥- ការបន្តដំណើរការអាជីវកម្ម ដើម្បីជានានិរន្តរភាពនៃវត្ថុចាប់យកដែលពាក់ព័ន្ធនឹងសហគ្រាស ឬអាជីវកម្ម ឬពាណិជ្ជកម្មដែលកំពុងដំណើរការ ដោយរក្សាទុកនូវរចនាសម្ព័ន្ធគ្រប់គ្រងដែលមានស្រាប់នៅដដែល ឬកែសម្រួលជាថ្មី ឬចាត់តាំងអភិបាលបណ្ដោះអាសន្ន ឬអ្នកជំនាញផ្សេងទៀត ដើម្បីគ្រប់គ្រង និងចាត់ចែងសកម្មភាពអាជីវកម្ម ឬពាណិជ្ជកម្ម ដែលកំពុងដំណើរការនោះ
៦- ការចាត់តាំងនូវតំណាងដើម្បីការពារសិទ្ធិលើវត្ថុចាប់យកនៅក្នុងដំណើរការនីតិវិធីនានាដែលពាក់ព័ន្ធនឹងតតិយជន
៧- របៀបនៃការចាត់ចែងផ្សេងទៀតដោយផ្អែកលើលក្ខណៈពិសេស ឬស្ថានភាពពិសេសនៃវត្ថុចាប់យក។

ការសម្រេចអំពីវិធី ឬរបៀបណាមួយនៃការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវធ្វើឡើងដោយដីកាសម្រេចរបស់អង្គការអយ្យការ ឬតុលាការដែលមានសមត្ថកិច្ច។

នៅក្នុងគ្រប់ករណីទាំងអស់ **គ.អ.ច.ប.** ត្រូវទទួលខុសត្រូវក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកតាមវិធី ឬរបៀបខាងលើ ព្រមទាំងលើកយោបល់នានាជូនអង្គការអយ្យការ ឬតុលាការដែលមានសមត្ថកិច្ច ដើម្បីពិនិត្យ និងសម្រេច ដោយយោងតាមការចាំបាច់ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក ឬដើម្បីធានាតម្លៃសេដ្ឋកិច្ច ឬផលប្រយោជន៍សេដ្ឋកិច្ចនៃវត្ថុចាប់យក។

**ប្រការ៧.-**

ក្នុងការអនុវត្តចំណុចទី៥ នៃប្រការ៦ នៃប្រកាសនេះ អភិបាលបណ្ដោះអាសន្នត្រូវជ្រើសចេញពីបញ្ជីថ្នាក់ជាតិនៃអភិបាលបណ្ដោះអាសន្ន និងអ្នកជំនាញផ្សេងទៀតត្រូវទទួលស្គាល់ដោយក្រសួងយុត្តិធម៌។

អភិបាលបណ្ដោះអាសន្ន និងអ្នកជំនាញដែលទទួលបានការចាត់តាំង ត្រូវបំពេញការងាររបស់ខ្លួនតាមអាណត្តិដែលប្រគល់នៅក្នុងដីកាសម្រេចរបស់អង្គការអយ្យការ ឬតុលាការដែលមានសមត្ថកិច្ច។

**ប្រការ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្ត និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- គ្រប់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ